# GC ជីវិតប្រសើរ



## តើអ្វីទៅជា GC ជីវិតប្រសើរ ?

GC ជីវិតប្រសើរ គឺជាគម្រោងធានារ៉ាប់រងមានកាលកំណត់រយៈពេល 5 ទៅ 30ឆ្នាំ ដែលផ្តល់នូវការការពារខ្ពស់ជាមួយនឹងទឹកប្រាក់ផ្តល់ត្រឡប់វិញដែលស្មើនឹងបុព្វលាភប្រចាំឆ្នាំដែលលោកអ្នកបានបង់ទាំងអស់។

## តើអ្នកណាអាចទទួលបានការធានាពីគម្រោងមួយនេះ ?

បុគ្គលដែលមានអាយុចន្លោះពី 1 - 60ឆ្នាំ។

## ហេតុអ្វីបានជាចាំបាច់ជ្រើសរើស GC ជីវិតប្រសើរ ?

GC ជីវិតប្រសើរ គឺជាគម្រោងធានារ៉ាប់រងដែលមានភាពបត់បែនច្រើន។ គម្រោងធានារ៉ាប់រងនេះមានជម្រើស និងរយៈពេលធានារ៉ាប់រងជាច្រើនសម្រាប់លោកអ្នកជ្រើសរើស។ ក្រៅពីការការពារលើមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ លោកអ្នកអាចបន្ថែមនូវ អត្ថប្រយោជន៍ការពារបន្ថែមលើគ្រោះថ្នាក់ជាយថាហេតុ រហូតដល់ **5ដង** នៃទឹកប្រាក់ត្រូវបានធានារបស់ផលិតផល GC ជីវិតប្រសើរ។ លើសពីនេះទៅទៀត លោកអ្នកក៏អាចបន្ថែមនូវ អត្ថប្រយោជន៍លើការព្យាបាលជំងឺធ្ងន់ធ្ងរ ដើម្បីការពារលើការចំណាយក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញជំងឺធ្ងន់ធ្ងរកម្រិតដំបូង និងកម្រិតធ្ងន់។ អ្វីដែលពិសេសនោះ ប្រសិនបើលោកអ្នកមានសុខភាពល្អ រហូតដល់ពេលដែលកិច្ចសន្យាដល់កាលកំណត់ លោកអ្នកនឹងអាចទទួលបានបុព្វលាភប្រចាំឆ្នាំនៃផលិតផល GC ជីវិតប្រសើរ ដែលលោកអ្នកបានបង់ទាំងអស់ត្រឡប់ទៅវិញផងដែរ។

## អត្ថប្រយោជន៍ធានារ៉ាប់រង

**សំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

100% នៃទឹកប្រាក់ត្រូវបានធានា

**អត្ថប្រយោជន៍ផ្តល់ត្រឡប់សាច់ប្រាក់**

ផ្តល់ត្រឡប់នូវបុព្វលាភប្រចាំឆ្នាំដែលបានបង់ទាំងអស់វិញ

(បុព្វលាភប្រចាំឆ្នាំនៃផលិតផលមូលដ្ឋាន x រយៈពេលបង់បុព្វលាភ)

## ទទួលបានការការពារកាន់តែប្រសើរដោយ បន្ថែមនូវអត្ថប្រយោជន៍ខាងក្រោម៖

### អត្ថប្រយោជន៍ការពារបន្ថែមលើ គ្រោះថ្នាក់ជាយថាហេតុ

គ្រោះថ្នាក់ជាយថាហេតុធម្មតា

100% នៃទឹកប្រាក់ត្រូវបានធានារបស់ធានារ៉ាប់រងបន្ថែម

មធ្យោបាយធ្វើដំណើរសាធារណៈ

200% នៃទឹកប្រាក់ត្រូវបានធានារបស់ធានារ៉ាប់រងបន្ថែម

មធ្យោបាយធ្វើដំណើរសាធារណៈ + ថ្ងៃឈប់សម្រាកបុណ្យជាតិ

300% នៃទឹកប្រាក់ត្រូវបានធានារបស់ធានារ៉ាប់រងបន្ថែម

### អត្ថប្រយោជន៍លើការព្យាបាលជំងឺធ្ងន់ធ្ងរ

**ជំងឺធ្ងន់ធ្ងរកម្រិតដំបូង**

25% នៃទឹកប្រាក់ត្រូវបានធានារបស់ធានារ៉ាប់រងបន្ថែម

**ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់**

100% នៃទឹកប្រាក់ត្រូវបានធានារបស់ធានារ៉ាប់រងបន្ថែម

# ការបង្ហាញអំពីអត្ថប្រយោជន៍ធានារ៉ាប់រង



## អ្នកស្រីម៉ាលី / ២៥ឆ្នាំ

**ឧទាហរណ៍ទី ១**

អ្នកស្រីបានទិញនូវផលិតផល GC ជីវិតប្រសើរ ដែលមានទឹកប្រាក់ត្រូវបានធានា $50,000 រយៈពេលធានារ៉ាប់រង 20ឆ្នាំ និងរយៈពេលបង់បុព្វលាភ 20ឆ្នាំ។ អ្នកស្រីបានបន្ថែមនូវ អត្ថប្រយោជន៍ការពារបន្ថែមលើគ្រោះថ្នាក់ជាយថាហេតុ ដែលមានទឹកប្រាក់ត្រូវបានធានា $250,000 និង អត្ថប្រយោជន៍លើការព្យាបាលជំងឺធ្ងន់ធ្ងរ ដែលមានទឹកប្រាក់ត្រូវបានធានា $50,000។

បុព្វលាភប្រចាំឆ្នាំសរុបដែលអ្នកស្រីត្រូវបង់គឺ **$1,345.50**



**ឧទាហរណ៍ទី ២** អ្នកស្រីបានទិញនូវផលិតផល GC ជីវិតប្រសើរ ដែលមានទឹកប្រាក់ត្រូវបានធានា $50,000 រយៈពេលធានារ៉ាប់រង 20ឆ្នាំ និងរយៈពេលបង់បុព្វលាភ 20ឆ្នាំ។

បុព្វលាភប្រចាំឆ្នាំដែលអ្នកស្រីត្រូវបង់គឺ **$855**



# លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 1 - 60ឆ្នាំ |
| រយៈពេលធានារ៉ាប់រង/<br>រយៈពេលបង់បុព្វលាភ | 5 - 30ឆ្នាំ |
| វិធីសាស្ត្របង់បុព្វលាភ | ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំខែ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $5,000ឡើង<br>( សម្រាប់រយៈពេលធានារ៉ាប់រង 5 - 9ឆ្នាំ ចាប់ពី $20,000ឡើង ) |

ការផ្តល់ត្រឡប់នូវបុព្វលាភ

សំណងខ្ពស់

ជម្រើសច្រើន



# ករណីមិនធានា

**១. មរណភាព**

មិនមានអត្ថប្រយោជន៍លើមរណភាពនឹងត្រូវផ្តល់ជូននោះទេ ប្រសិនបើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានបង្កឡើង ដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖
(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយ។
(២) ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែងការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។
(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លេចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬរោគសញ្ញាផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

ក្រុមហ៊ុនមិនធានាលើការបាត់បង់ ឬពិការភាពដែលបណ្តាលមកពីព្រឹត្តិការណ៍ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលទាំងស្រុង ឬ ដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖
(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
(២) ការឆ្លងវីរុសហ៊ីវ (HIV) រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។
(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាពប្រឆាំងនឹងរដ្ឋាភិបាលនិងអំពើភេរវកម្ម។
(៤) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។
(៥) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើការជាប្រចាំ និងទៀងទាត់តាមកាលវិភាគ និងគន្លងធ្វើដំណើរផ្លូវអាកាសដែលបានកំណត់របស់ក្រុមហ៊ុន។
(៦) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្ត ចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។
(៧) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖
	១) អ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល
	២) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ
	៣) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ
	៤) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។
(៨) អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ  លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។
(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

អគារ C ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ